Asian American Health Initiative

# សន្លឹកព័ត៌មានពីរោគមហារីកកស្បូន

## តើរោគមហារីកកស្បូនគឺជាអ្វី ?

រោគមហារីកកស្បូនគឺជាជម្ងឺមួយដែលបណ្ដាលមកពីការរីកធំ និងបំណែងចែកមិនធម្មតានៃកោសិកាដែលបង្កើតបានជាកស្បូន ដែលមានលក្ខណៈតូចចង្អៀតនៅខាងចុងផុតនៃស្បូន ។ ស្បូនគឺជាសរីរាង្គប្រហោងដែលជាកន្លែងទារករីកលូតលាស់ក្នុងកំឡុងពេលមានផ្ទៃពោះរបស់ស្ត្រី ។







## កត្តាប្រថុយគ្រោះថ្នាក់

កត្តាប្រថុយគ្រោះថ្នាក់រោគមហារីកកស្បូនរួមមានដូចជា :

- ការឆ្លងវីរុសសាច់ដុះក្នុងសុដន់មនុស្ស (HPV)
- ដៃគូរួមភេទច្រើន
- មានការរួមភេទនៅអាយុតិចពេក
- ពិសាបារី
- ផ្តល់កំណើតកូនច្រើនពេក
- ការប្រើប្រាស់ថ្នាំពន្យាកំណើតតាមមាត់ (“ថ្នាំលេប”)
- ប្រវត្តិគ្រួសារ
- តំណមអាហារ

## រោគសញ្ញា

ជាទូទៅរោគមហារីកកស្បូនពីដំបូង មិនមានសញ្ញា ឬរោគសញ្ញាអ្វីនោះទេ ។ ពេលដែលរោគមហារីកនេះរីកធំ សញ្ញា និងរោគសញ្ញាអាចមានដូចជា :

- ហូរឈាមតាមរន្ធយោនី
- ឈាមរដូវមិនធម្មតា
- ឈឺត្រគាក
- ឈឺចាប់ក្នុងកំឡុងពេលរួមភេទ

## ការបង្ការ/ការរកឃើញទាន់ពេល

មធ្យោបាយមានប្រសិទ្ធិភាពបំផុតដើម្បីបង្ការកស្បូនគឺ ការពិនិត្យត្រគាកដែលរួមមាន**ការធ្វើតេស្ដ៍ Pap (Pap test)** ។ **ការធ្វើតេស្ដ៍ Pap (Pap test)** គឺជាមធ្យោបាយស្វែងរកការប្រែប្រួលមិនធម្មតាក្នុងកស្បូនដែលអាចបណ្ដាលឱ្យមានរោគមហារីក ប្រសិនបើទុកចោលមិនព្យាបាល ។

## ការណែនាំពិនិត្យរោគមហារីកកស្បូន

ចាប់ផ្តើមពីអាយុ 21 អ្នកគួរតែធ្វើ :

- **តេស្ត៍ Pap (Pap test) រៀងរាល់ 3 ឆ្នាំម្តង (ទោះបីជាអ្នកមិនទាន់មានការរួមភេទក៏ដោយ)**

ប្រសិនបើអ្នកធ្លាប់មានការរួមភេទមុនពេលអាយុ 21 :

- **តេស្ត៍ Pap (Pap test) រៀងរាល់ 3 ឆ្នាំម្តង បន្ទាប់ពីអ្នកបានរួមភេទជាលើកដំបូង**

ប្រសិនបើអ្នកមានអាយុ 40 ឆ្នាំ ឬលើសពីនេះ :

- **តេស្ត៍ Pap (Pap test) រៀងរាល់ឆ្នាំ**

## ការពិនិត្យរោគវិនិច្ឆ័យ និងការព្យាបាល

ការព្យាបាលអ្នកជម្ងឺដែលមានរោគមហារីកកស្បូន ផ្អែកទៅលើដំណាក់កាលនៃជម្ងឺនេះ ។

- **ការវះកាត់** គឺជាការយករោគមហារីកចេញក្នុងការវះកាត់ ។
- **ការព្យាបាលដោយកាំរស្មី** គឺជាការព្យាបាលរោគមហារីកដែលប្រើប្រាស់កាំរស្មីអ៊ិច ដើម្បីសម្លាប់កោសិការោគមហារីក ។
- **ការព្យាបាលតាមបែបគីមីសាស្រ្ត** ប្រើប្រាស់ថ្នាំដើម្បីបញ្ឈប់ការរីកធំរបស់កោសិការោគមហារីក ។

## សន្និដ្ឋាន

ស្រ្តីអាស៊ីកាត់អាមេរិក មានអត្រាមួយក្នុងចំណោមអត្រារោគមហារីកកស្បូនខ្ពស់បំផុត ដោយសារតែអត្រាពិនិត្យទាប ។ ប្រសិនបើស្រ្តីកាន់តែច្រើនមានការធ្វើតេស្ត៍ pap smears បានជាប់ជាប្រចាំ នោះនឹងមានករណីនេះកាន់តែតិច ហើយអត្រាព្យាបាលទាំងមូល នឹងមានរហូតដល់ជាង 90 ភាគរយ ។ ការរកឃើញទាន់ពេលនូវការប្រែប្រួលមិនធម្មតា អាចជួយសង្គ្រោះជីវិតបាន ។

### ចូរចងចាំថា ការរកឃើញទាន់ពេលជួយសង្គ្រោះជីវិតបាន !

សម្រាប់ព័ត៌មានបន្ថែមពីកម្មវិធីពិនិត្យរោគមហារីករបស់យើង សូម**ទូរស័ព្ទទៅលេខ 240-777-1409** ឬចូលទៅកាន់គេហទំព័ររបស់យើងតាម **www.AAHIinfo.org** ។

ប្រភព

***American Cancer Society, ehealthMD, Intercultural Cancer Council, National Cancer Institute, University of Southern California.***